**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**

ថ្ងៃ...សុក្រ ៧កើត......ខែ...ជេស្ឋ.....ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី...២៦.....ខែ...ឧសភា....ឆ្នាំ២០២៣

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពីលទ្ធផលមហាសន្និបាតភាគហ៊ុនិកលើកទី១១ របស់រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ (រ.ទ.ស.ភ) សូមជម្រាបជូនវិនិយោគិន និងសាធារណជន មេត្តាជ្រាបថា ៖ នាថ្ងៃសុក្រ ៧កើត ខែជេស្ឋ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៣ ចាប់ពីម៉ោង ៨:០០ព្រឹក មហាសន្និបាតភាគហ៊ុនិកលើកទី១១ របស់ រ.ទ.ស.ភ តាមប្រព័ន្ធអនឡាញ ZOOM បានដំណើរការទៅតាមកម្មវិធីដែលបានគ្រោងទុក។ មហាសន្និបាត នាពេលនេះ ស្ថិតក្រោមអធិបតីភាព **ឯកឧត្តម ស៊ឹម ស៊ីថា** ប្រធានក្រុមប្រឹក្សាភិបាល រ.ទ.ស.ភ ដោយមានការចូលរួមពីភាគហ៊ុនិកសរុប១៨០រូប គិតជាភាគហ៊ុន មានចំនួន ៧៥.៧៦៦.៤៤៨ ស្មើនឹង ៨៧,១១% នៃចំនួនភាគហ៊ុនធម្មតាសរុប ក្នុងនោះមាន **ឯកឧត្តម ម៉ី វ៉ាន់** រដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាតំណាងអាណត្តិគាហកៈរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

មហាសន្និបាតនេះបានប្រព្រឹត្តទៅតាមរបៀបវារៈដូចបានកំណត់ទុក ដែលមានខ្លឹមសារ និងទទួលបានលទ្ធផលដូចខាងក្រោម ៖

**១) របាយការណ៍លទ្ធផលអាជីវកម្មឆ្នាំ២០២២**

| | |
|---|---|
| - ផលិតទឹកស្អាតបាន | ២៣៩.២០៨.៦៥៧ម$^{៣}$ |
| - បង្កើនអតិថិជនថ្មីបានចំនួន | ២៣.៨០០បណ្តាញ |
| - ចំណូលសរុបមានចំនួន | ៣៤៦.១៧៨.១៥៦.០០០រៀល |
| - ចំណេញក្រោយបង់ពន្ធមានចំនួន | ១០៨.១៨៥.៨៦៥.០០០រៀល |
| - ចំណេញជាមូលដ្ឋានក្នុងមួយភាគហ៊ុនគឺ | ១.២៤៣,៩០រៀល |

**២) ទិសដៅអាជីវកម្មឆ្នាំ២០២៣**

| | |
|---|---|
| - ផលិតទឹកស្អាត | ២៧២.២៦៣.១០០ម$^{៣}$ |
| - បង្កើនអតិថិជនថ្មីចំនួន | ៣៦.០០០បណ្តាញ |
| - ចំណូលសរុប | ៤១៣.៨៥៥.៤៣៦.០០០រៀល |
| - ចំណាយសរុប | ២៦៧.៩៤០.០៩០.០០០រៀល |
| - ចំណេញក្រោយបង់ពន្ធ | ១១៦.៧៨១.២៦០.០០០រៀល |

**៣) ការបោះឆ្នោតទៅលើកម្មវត្ថុចំនួន២ គឺ៖**

**ក) ការអនុម័តលើការបែងចែកភាគលាភជូនភាគហ៊ុនិក**

ការបោះឆ្នោតនេះ មានការចូលរួមពីភាគហ៊ុនិកចំនួន១៦៩រូប លើភាគហ៊ុនិកវត្តមានសរុប១៨០រូប គិតជាភាគហ៊ុនមានចំនួន ៧៥.៧៥២.១៩៤ភាគហ៊ុន ស្មើនឹង៩៩,៩៨%។



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh

មហាសន្និបាតបានឯកភាពបែងចែកភាគលាភឆ្នាំ២០២២ ជាសាច់ប្រាក់ចំនួន ២៨.៧០១.១៤៣.៤៦០រៀល ជូនដល់ភាគហ៊ុនិកដែលមានឈ្មោះក្នុងបញ្ជីភាគហ៊ុនិក នាកាលបរិច្ឆេទកំណត់ទុកថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣ ដោយមានសំឡេងបោះឆ្នោតគាំទ្រ ចំនួន ៧៥.៧៥២.០៩៤សំឡេង ស្មើនឹង ៩៩,៩៨% នៃភាគហ៊ុនវត្តមានសរុប លើសំឡេង អនុប្បវាទចំនួន ១០០សំឡេង ស្មើនឹង ០,០០០១% នៃភាគហ៊ុនវត្តមានសរុប។ ទឹកប្រាក់ នេះនឹងត្រូវចែកជូនភាគហ៊ុនិក ចាប់ពីថ្ងៃទី២០ ខែមិថុនា ឆ្នាំ២០២៣ ដល់ថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០២៣ ក្នុងទឹកប្រាក់ ៣៣០រៀល/ភាគហ៊ុន។

**ខ) ការអនុម័តលើលាភការរបស់ក្រុមប្រឹក្សាភិបាល**

ការបោះឆ្នោតនេះ មានការចូលរួមពីភាគហ៊ុនិកចំនួន១៦៩រូប លើភាគហ៊ុនិកវត្តមាន សរុប១៨០រូប គិតជាភាគហ៊ុនមានចំនួន ៧៥.៧៥២.១៩៤ភាគហ៊ុន ស្មើនឹង៩៩,៩៨%។

មហាសន្និបាតបានឯកភាពទៅលើលាភការរបស់សមាជិកក្រុមប្រឹក្សាភិបាលចំនួន៧រូប និងមន្ត្រីត្រួតពិនិត្យរដ្ឋអម រ.ទ.ស.ភ ចំនួន១រូប សម្រាប់ឆ្នាំ២០២៣ ដែលមានទឹកប្រាក់សរុប ចំនួន ១.១០៧.៩៧៩.០០០រៀល ដោយមានសំឡេងបោះឆ្នោតគាំទ្រចំនួន ៧៥.៧៤២.១១៤ សំឡេង ស្មើនឹង ៩៩,៩៧% នៃភាគហ៊ុនវត្តមានសរុប លើសំឡេងមិនគាំទ្រចំនួន ២៦៩សំឡេង ស្មើនឹង ០,០០០៤% នៃភាគហ៊ុនវត្តមានសរុប និងសំឡេងអនុប្បវាទចំនួន ៩.៨១១សំឡេង ស្មើនឹង ០,០១% នៃភាគហ៊ុនវត្តមានសរុប។

អង្គមហាសន្និបាតនេះបានវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញភារកិច្ចយ៉ាងសកម្មរបស់ បុគ្គលិក និយោជិត កម្មករ នៃ រ.ទ.ស.ភ គ្រប់លំដាប់ថ្នាក់ គ្រប់ផ្នែកពាក់ព័ន្ធ ដែលបានចូលរួមបង្កើតស្នាដៃ និង សមិទ្ធផលថ្មីៗជំពេងជាច្រើន ក្នុងការទ្រទ្រង់និងជំរុញសកម្មភាពការងាររបស់ រ.ទ.ស.ភ ឆ្លើយតបទៅនឹងសំណូមពរ នៃការផលិតនិងផ្គត់ផ្គង់ទឹកស្អាតជូនដល់ប្រជាពលរដ្ឋ និងតម្រូវការផ្នែកអាជីវកម្ម សេវាកម្ម រួមទាំងជីវភាពសង្គម នានាក្នុងរាជធានីភ្នំពេញ។ អង្គមហាសន្និបាតក៏បានគាំទ្រគម្រោងអាទិភាពក្នុងការពង្រីកសមត្ថភាពផ្គត់ផ្គង់ទឹកស្អាត របស់ រ.ទ.ស.ភ ដែលបង្ហាញជូនអង្គមហាសន្និបាត និងបានគូសបញ្ជាក់អំពីទិសដៅជាយុទ្ធសាស្ត្រ ដែលត្រូវសម្រេច ឱ្យបាននូវគោលនយោបាយផ្គត់ផ្គង់ទឹកស្អាតទីប្រជុំជនឱ្យបាន១០០% នៅឆ្នាំ២០២៥ និងគោលដៅផ្គត់ផ្គង់ទឹកស្អាត នៅរាជធានីភ្នំពេញឆ្នាំ២០៣០ ផ្អែកតាមផែនការមេដំណាក់កាលទី៣ (ឆ្នាំ២០២១-២០៣០) របស់រដ្ឋាករទឹក ស្វយ័តក្រុងភ្នំពេញ។

អង្គមហាសន្និបាតបានបញ្ចប់នៅវេលាម៉ោង ១១:៥០ព្រឹក នាថ្ងៃខែនិងឆ្នាំដដែល ដោយស្ថិតក្រោម បរិយាកាសស្និទ្ធស្នាល រីករាយ និងទទួលខុសត្រូវ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមវិនិយោគិន និងសាធារណជនទទួលជ្រាបជាព័ត៌មាន។

**រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ**



អគារ៤៥ ផ្លូវ១០៦ សង្កាត់ស្រះចក ខណ្ឌដូនពេញ ភ្នំពេញ ទូរស័ព្ទ: (៨៥៥)២៣ ៦៣៥ ៨០ ៨០ Email: admin@ppwsa.com.kh